# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៥៧.សសរ

## សេចក្តីសំរេច
## ស្តីពី
## ការបង្កើតគណៈកម្មការចំរុះ នៃកិច្ចសហប្រតិបត្តិការ
## កម្ពុជា_ហ្វីលីពីន

*****

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- យោងស្មារតីនៃកិច្ចព្រមព្រៀង រវាងរាជរដ្ឋាភិបាលកម្ពុជានិងរដ្ឋាភិបាលនៃសាធារណរដ្ឋហ្វីលីពីន ស្តីពីការបង្កើតគណៈកម្មការចំរុះ សំរាប់កិច្ចសហប្រតិបត្តិការទ្វេភាគី ចុះថ្ងៃទី ១៦ ខែ សីហា ឆ្នាំ ២០០០ នៅទីក្រុងម៉ានីល
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ

### សំរេច

**ប្រការ ១:** បង្កើតគណៈកម្មការចំរុះខាងភាគីកម្ពុជា ដែលមានសមាសភាពដូចខាងក្រោម ដើម្បីសំរួលដល់ការពិគ្រោះយោបល់ និង កិច្ចសហប្រតិបត្តិការ រវាងព្រះរាជាណាចក្រកម្ពុជា និង សាធារណរដ្ឋហ្វីលីពីន ជាពិសេសខាងវិស័យនយោបាយ សេដ្ឋកិច្ច ពាណិជ្ជកម្ម សង្គម វប្បធម៌ និង វិស័យដទៃទៀត ដែលមានប្រយោជន៍ទៅវិញទៅមក :

| | | |
|---|---|---|
| ១- | រដ្ឋមន្ត្រី ឬ រដ្ឋលេខាធិការ ក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ | ប្រធាន |
| ២- | ឯកអគ្គរាជទូតកម្ពុជាប្រចាំសាធារណរដ្ឋហ្វីលីពីន | សមាជិក |
| ៣- | តំណាងទីស្តីការគណៈរដ្ឋមន្ត្រី | សមាជិក |
| ៤- | តំណាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |
| ៥- | តំណាងក្រសួងពាណិជ្ជកម្ម | សមាជិក |
| ៦- | តំណាងក្រសួងអប់រំ យុវជន និងកីឡា | សមាជិក |
| ៧- | តំណាងក្រសួងកសិកម្ម រុក្ខា ប្រមាញ់ និងនេសាទ | សមាជិក |

| | | |
|---|---|---|
| ៨- | តំណាងក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល | សមាជិក |
| ៩- | តំណាងក្រសួងទេសចរណ៍ | សមាជិក |
| ១០- | តំណាងក្រសួងសុខាភិបាល | សមាជិក |
| ១១- | តំណាងក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា | សមាជិក |
| ១២- | ប្រធាននាយកដ្ឋានអាស៊ី នៃក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ | លេខាប្រតិបត្តិ |

**ប្រការ ២ :** គណៈកម្មការចំរុះនេះ មានបេសកកម្ម ដូចខាងក្រោមៈ

- ពិនិត្យការអនុវត្តកិច្ចព្រមព្រៀង និងពិភាក្សាបញ្ហាទាំងឡាយ ដែលអាចកើតមានឡើងពីការអនុវត្ត កិច្ចព្រមព្រៀងសហប្រតិបត្តិការលើវិស័យនានា ដូចបានលើកឡើងក្នុងប្រការ ១ ហើយនិងបង្កើតអនុសាសន៍សំខាន់ៗ ទាំងឡាយ ដើម្បីសំរេចគោលដៅរបស់ខ្លួន។
- គណៈកម្មការចំរុះនេះ នឹងជួបប្រជុំគ្នាជាមួយគណៈកម្មការ ខាងភាគីហ្វីលីពីន តាមការព្រមព្រៀងគ្នាជាមុន ដោយឆ្លាស់គ្នាម្តងម្នាក់ នៅប្រទេសហ្វីលីពីន និង នៅប្រទេសកម្ពុជា។

**ប្រការ ៣:** ដើម្បីបំពេញបេសកកម្មខាងលើ គណៈកម្មការនេះមានភារកិច្ច និង សិទ្ធិ :

- សហការជាមួយក្រសួងនិងស្ថាប័នពាក់ព័ន្ធ ដើម្បីរៀបចំឯកសារកម្មវិធីនៃសកម្មភាព ក្នុងការគ្រប់គ្រង និង ជំរុញកិច្ចសហប្រតិបត្តិការ រវាងប្រទេសទាំងពីរកម្ពុជានិងហ្វីលីពីន ក្នុងទិសដៅអភិវឌ្ឍវិស័យនានា ដែលបានព្រមព្រៀងគ្នា ដោយរដ្ឋាភិបាលទាំងពីរ។
- ចូលរួមប្រជុំ និងធ្វើទំនាក់ទំនងផ្ទាល់ ជាមួយគណៈកម្មការ ខាងភាគីហ្វីលីពីន និងអង្គការអន្តរជាតិនានា ដើម្បីដោះស្រាយការងារពាក់ព័ន្ធ។
- ធ្វើរបាយការណ៍អំពីលទ្ធផលការងារ ជូនរាជរដ្ឋាភិបាល ដើម្បីសុំមតិណែនាំ និងគោលការណ៍សំរេច។
- ក្នុងករណីចាំបាច់ គណៈកម្មការចំរុះនេះ អាចបង្កើតក្រុមការងារ និង តែងតាំងអ្នកជំនាញការឬទីប្រឹក្សា ដើម្បីចូលរួមប្រជុំ។

**ប្រការ ៤:** សមាជិកនៃគណៈកម្មការចំរុះនេះ ត្រូវចូលរួមប្រជុំតាមការអញ្ជើញនិងក្រោមការដឹកនាំ របស់ប្រធានគណៈកម្មការ។ ក្នុងករណីសមាជិកណាម្នាក់ មិនបានចូលរួមប្រជុំ ដោយជាប់រវល់ភារកិច្ច ត្រូវចាត់តំណាងដែលមានសិទ្ធិសំរេច អោយចូលរួមប្រជុំជំនួស។

**ប្រការ ៥:** គណកម្មការចំរុះ កម្ពុជា-ហ្វីលីពីន មានលេខាធិការដ្ឋាន ដែលមានទីតាំងនៅក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ ហើយមានសិទ្ធិប្រើប្រាស់ត្រា របស់ក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ ក្នុងករណីចាំបាច់ និង មានសិទ្ធិអញ្ជើញអ្នកជំនាញឯកទេស មកពីគ្រប់ក្រសួងនិងស្ថាប័នពាក់ព័ន្ធ អោយចូលរួមប្រជុំ ឬជួយបំពេញការងារ ក្នុងឋានៈជាជំនួយការបច្ចេកទេស។ លេខាធិការដ្ឋាននៃគណៈកម្មការចំរុះ កម្ពុជា-ហ្វីលីពីន មានប្រធាននាយកដ្ឋានអាស៊ី នៃក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ ជាលេខាធិការប្រតិបត្តិ។

**ប្រការ ៦:** ក្រសួងស្ថាប័ននីមួយៗ ត្រូវបញ្ជូនឈ្មោះនិងមុខងារនៃតំណាងរបស់ខ្លួន ដូចមានចែងក្នុងប្រការ ១ មកប្រធានគណៈកម្មការចំរុះនេះ ដើម្បីងាយស្រួលក្នុងការបំពេញភារកិច្ចរបស់គណៈកម្មការ ។

**ប្រការ ៧:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខា ប្រមាញ់ និងនេសាទ រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល រដ្ឋមន្ត្រីក្រសួងទេសចរណ៍ រដ្ឋមន្ត្រីក្រសួងសុខាភិបាល ប្រធានក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា និង សាមីខ្លួន ដូចមានចែងក្នុងប្រការ ១ ត្រូវអនុវត្តសេចក្តីសំរេចនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ភ្នំពេញ ថ្ងៃទី [illegible]៥ ខែ សីហា ឆ្នាំ ២០០១

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

ចំលងជូន :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចប្រការ ៧ "ដើម្បីអនុវត្ត"
- ឯកសារ - កាលប្បវត្តិ